ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលមាត្រា ១ និងមាត្រា ៣ វាក្យខ័ណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាយោធា

+++++

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១.-**

ត្រូវបានកែសំរួលមាត្រា ១ និងមាត្រា ៣ វាក្យខ័ណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា ដែលមានខ្លឹមសារដូចតទៅ ៖

**មាត្រា ១ថ្មី.-** បង្កើតក្រុមប្រឹក្សាយោធាមួយ ដោយអនុលោមតាមមាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ហើយដែលមានសមាសភាព ៖

- រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធានអចិន្ត្រៃយ៍
- អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ សមាជិក
- អនុរដ្ឋលេខាធិការក្រសួងការពារជាតិ មួយរូប សមាជិក
- នាយរងសេនាធិការចំរុះ មួយចំនួន សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងកងទ័ពជើងគោក កងទ័ពជើងអាកាស កងទ័ពជើងទឹក និងកងរាជអាវុធហត្ថ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអគ្គនាយកដ្ឋានទាំងបី នៃក្រសួងការពារជាតិ សមាជិក
- នាយទាហានថ្នាក់ឧត្តមសេនីយ៍មួយរូបៗ តំណាងអោយស្ថាប័ន អធិការកិច្ច អយ្យការយោធា តុលាការយោធា វិទ្យាស្ថានយោធាកម្ពុជា ខុទ្ទកាល័យ ក្រសួងការពារជាតិ ទីចាត់ការហិរញ្ញវត្ថុ ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន សមាជិក
- នាយទាហានជាន់ខ្ពស់មួយរូបៗ តំណាងអោយគ្រប់យោធភូមិភាគ និងបណ្តាកងពលចំណុះអគ្គបញ្ជាការ សមាជិក
- នាយក នាយកដ្ឋាននីតិកម្មក្រសួងការពារជាតិ លេខាធិការ
- នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ លេខាធិការរង
- នាយក ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ លេខាធិការរង

**មាត្រា ៣ថ្មី.-** ក្រុមប្រឹក្សាយោធា ត្រូវប្រជុំពិនិត្យស្រាវជ្រាវ និងប្រជុំពេញអង្គ ៖

- ការប្រជុំពិនិត្យស្រាវជ្រាវប្រព្រឹត្តទៅក្រោមអធិបតីភាពនៃតំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាចអញ្ជើញបន្ថែមសមាសភាពដែលមានការពាក់ព័ន្ធចូលរួម
- ការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសំរេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រី ក្រសួងការពារជាតិ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- អគ្គបញ្ជាការដ្ឋាន
- ដូចមាត្រា ១ និង២
- កាលប្បវត្តិ-ឯកសារ

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ទៀ បាញ់** **ស៊ីសុវត្ថិ សិរីរ័ត្ន**